ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភារដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៨៥

ចុះថ្ងៃទី០៩ខែកុម្ភៈឆ្នាំ២០០០

សាលដីកា

លេខ : ១០

ចុះថ្ងៃទី១៦ខែមករាឆ្នាំ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្នី ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២- លោក ប៉ែន ស៊ុន ជាចៅក្រមរបាយការណ៍

៣- លោក ជីវ កេង ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម

៥- លោក ឃឹម ស៊ីផល ជាចៅក្រម

៦- លោក ប្រាក់ គីមសាន ជាចៅក្រម

៧- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៨- លោក យស់ សុខឿន ជាចៅក្រម

៩- លោក តង់ ភីរុណ ជាចៅក្រម

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

ឯកឧត្តម ដួន ស៊ុនទៀង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីកាលេខ ៧៩៧ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ០៤ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ប៊ូ សយ អាយុ ៥១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិធ្លកឃុល ឃុំពន្លៃ ស្រុកមង្គលបុរី ខេត្តតាកែវ ។

២- ឈ្មោះ ជួប សែន អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិធ្លកឃុល ឃុំពន្លៃ ស្រុកអង្គរបុរី ខេត្តតាកែវ ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ រឆ្ន រុន អាយុ ៥៦ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅពុភូមិស្នោ ឃុំកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារដីស្រែប្រាំងទំហំ ១ហិកតា ៦០អានិងទាមទារទិន្នផលស្រូវ ដែលចុងចម្លើយធ្វើកន្លងមក ៦០០តៅ ។

តាមបណ្តឹងសាទុក្ខលើកទី២ លេខ ៥៣៤ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ឈ្មោះ ប៊ូ សយ និង ជួប សែន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ៧៩៧ ចុះថ្ងៃទី០៨ ខែ-

វិច្ឆិកា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៨៥ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៥.៧.៩៥ របស់ដើមចោទឈ្មោះ រ័ត្ន រុន ប្តឹងទាមទារដីស្រែប្រាំងទំហំ១ហិកតា៦០អា និង ផលស្រូវ ៦០០តៅ ដោយហេតុថាដីនេះអាជ្ញាធរមានសមត្ថកិច្ចបានបែងចែកអោយខ្លួនកាលពីឆ្នាំ ១៩៩២ តែត្រូវចុងចម្លើយទៅធ្វើលើដីនោះរហូតមានទំនាស់គ្នាសព្វថ្ងៃនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៨១ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៥.០១.៩៥ របស់លោក រ័ត្ន រុន "ដើមចោទ" ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ ទទួលស្គាល់ថាសេចក្តីសំរេចលេខ ១៦៩សសរ ចុះថ្ងៃទី ២៥.១២.៩២ របស់លោក អភិបាលខេត្តតាកែវ មានលក្ខណៈសមស្របតាមទំរង់ និង គតិច្បាប់ ។

៣_ សំរេចថាដីទំនាស់រវាងដើមចោទឈ្មោះ រ័ត្ន រុន និង ចុងចម្លើយឈ្មោះ ប៊ូ សយ និង ឈ្មោះ ដួប សែន ដើមចោទឈ្មោះ រ័ត្ន រុន មានអភិភាពកាន់កាប់ប្រើប្រាស់ និង ធ្វើជាម្ចាស់កម្មសិទ្ធិតាមសេចក្តីសំរេចលេខ ១៦៩សសរ ចុះថ្ងៃទី ២៥.១២.៩២ របស់អភិបាលខេត្តតាកែវ ។

៤_ បង្គាប់អោយចុងចម្លើយឈ្មោះ ដួប សែន និង ប៊ូ សយ រួមគ្នាបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបណ្តឹងក្តី និង ពន្ធហ៊ឹង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល ចំណាយលើអ្នកប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ។ ប្រាក់នេះដកយកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួច ។ កាលបើផុតកំណត់ឧទ្ធរណ៍បង្គាប់អោយចុងចម្លើយទាំងពីរនាក់ សងប្រាក់ក្នុងម្នាក់ពុចំនួន ៣.៥០០រៀល អោយទៅដើមចោទវិញ ។

៥_ បង្គាប់អោយចុងចម្លើយទាំងពីរនាក់បង់ពន្ធសមាមាត្រមួយភាគរយលើតំលៃដីដែលតុលាការបានសំរេច ប្រាក់នេះបានបង់ចូលថវិការដ្ឋចំនួន ៨០ភាគរយ រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់ឈ្មោះ ប៊ូ សយ ប្តឹងមិនសុខចិត្តពីសាលក្រមរដ្ឋប្បវេណីលេខ ៨១ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់តុលាការខេត្តតាកែវ ត្រង់ចំនុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៣៥ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ប៊ូ សយ ចុះថ្ងៃទី ២៦.១២.៩៥ ទុកជាត្រឹម

--- ---

ត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៨១ ចុះថ្ងៃទី ២០.១២.៨៥ របស់តុលាការខេត្តតាកែវទុកជាបានការពេញទាំងមូល ។

៣_ រឹបអូសប្រាក់ប្រដាប់ក្តី ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀលចំណាយលើការប្រគល់ដីកាកោះ៥០០រៀល និង អាជ្ញាធរតុលាការ ៥.០០០រៀល ។

៤_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខឈ្មោះ រត្ន័ រុន កំបាំងមុខឈ្មោះ ជួប សែន និង ប៊ូ សយ បើកផ្លូវប្តឹងទាស់ និង ប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៨៧ របស់ឈ្មោះ ប៊ូ សយ ប្តឹងមិនសុខចិត្ត នឹង សាលដីកាលេខ ១២.៥.៨៧ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីកាលេខ ៧៤៧ ចុះថ្ងៃទី ១១.១២.៨៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងទាស់ចុះថ្ងៃទី ១៩.៨.៨៧ របស់ឈ្មោះ ប៊ូ សយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២_ តម្កល់សាលដីកាលេខ ៤៣៥ ចុះថ្ងៃទី ១២.៨.៨៧ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៥ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៨ របស់ឈ្មោះ ជួប សែន និង ប៊ូ សយ ប្តឹងមិនសុខចិត្ត នឹង សាលដីការដ្ឋប្បវេណីលេខ ៧៤៧ ចុះថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២២៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ១៩៨៨ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងសាទុក្ខលេខ ១៥ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៨ របស់លោក ប៊ូ សយ និង លោក ជួប សែន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៧៤៧ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ បញ្ជូលសំណុំរឿងរដ្ឋប្បវេណីលេខ ៩៣ ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ ១៩៨៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ជួប សែន និង លោ ប៊ូ សយ បានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន

--- ---

៤.០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវអោយលោក រ័ត្ន រុន សងប្រាក់ចំនួន ១៩.០០០រៀល ទៅលោក ប៊ូ សយ និង លោក ជួប សែន វិញ ។

៥- សាលដីកានេះប្រកាសទោសនំាការជាសាធារណៈនៅថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៩៧ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលសំណុំរឿងរដ្ឋប្បវេណីលេខ ០៤ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ជំនុំជំរះសាជាថ្មី តាមអំណាចសាលដីកាលេខ ២២៩ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

២- ប្រគល់ដីទំនាស់អោយឈ្មោះ រ័ត្ន រុន កាន់កាប់ជាកម្មសិទ្ធិ តាមសេចក្តីសំរេចលេខ ១០៩សសរ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩២ របស់អភិបាលខេត្តតាកែវ កាលណាសាលដីកានេះចូលជាស្ថាពរ ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍គឺ ពន្ធហ៊ឹង និង ពន្ធចុះបញ្ជីក្តីចំនួន ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ ចំណាយលើការប្រគល់ដីការកោះ ចំនួន ៥.០០០៛ និងលើអាជ្ញាធរតុលាការចំនួន ៥.០០០៛ សរុប ១៣.០០០៛ និងបង្គាប់អោយចុងចម្លើយឈ្មោះ ប៊ូ សយ និង ជួប សែន បង់ពន្ធសមាមាត្រចំនួន ១ភាគរយ នៃតំលៃដីទំនាស់ ។

សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី ២ លេខ ៥៣៤ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ឈ្មោះ ប៊ូ សយ និង ជួប សែន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ៧៩៧ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០០០របស់ឈ្មោះ ប៊ូ សយ និង ឈ្មោះ រ័ត្ន រុន ។

បានឃើញសារណាតបចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០០របស់ឈ្មោះរ័ត្ន រុន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណី លេខ ៧៩៧ ចុះថ្ងៃទី ៨.១១.៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់ ។

--- ---

បានស្តាប់ចម្លើយរបស់ឈ្មោះ ប៊ូ សយ ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខបាន ឆ្លើយនៅពេលសវនាការថា : ព្រោះដីនេះខ្លួនកាន់កាប់ស្របតាមច្បាប់ដែលរដ្ឋប្រគល់មកអោយខ្លួន ដោយមានការដោះដូរត្រឹមត្រូវហើយ ដីស្រែលើនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៨២ ហើយដូរជាមួយឈ្មោះ ផាំ និង គង់ សារិន តាំងពីឆ្នាំ ១៩៨៩ មក ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ជួប សែន ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខបាន ឆ្លើយនៅពេលសវនាការថា : ព្រោះដីនោះខ្លួនធ្វើតាំងពីឆ្នាំ ១៩៧៩មក ហើយបានដូរជាមួយ ទូច ផាំ និង សារិន នៅឆ្នាំ ១៩៨៩ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ រ័ត្ន រុន ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ បាន ឆ្លើយនៅពេលសវនាការថា : ដីទំនាស់ពីដើមនៅស្រុកដូនកែវ ហើយការឆ្លើយរបស់ទូចផាំ និង សារិន ជាការពិត ។ ហើយដីនេះខ្លួនបង្កបង្កើនផលតាំងពីឆ្នាំ ១៩៨៩ រហូតមក និង ដាក់ពាក្យសុំកាន់កាប់នៅឆ្នាំ ១៩៨៩ រដ្ឋប្រគល់អោយនៅឆ្នាំ ១៩៩០ ។ ដីនេះពីដើមក្រុមសាមគ្គីជាអ្នកធ្វើពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៥ ក៏ឈប់ទៅ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលើកទី២លេខ ៥៣៤ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់លោក ប៊ូ សយ និង ជួប សែន ប្តឹងពីសាលដីការដ្ឋប្បវេណីលេខ៧៩៧ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះរួមក្រុមដល់អង្គសេចក្តីបានតាមមាត្រា ១៥ នៃ ច្បាប់ស្តីពីការចាត់តាំង នឹង សកម្មភាពរបស់សាលាជំរះក្តី នឹង មាត្រា ២២៦ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា : ភាគីទាំងសងខាងសុទ្ធតែមានសំអាងហេតុ និង ភស្តុតាងសមហេតុ សមផលដូចគ្នា ប៉ុន្តែការដែលអាជ្ញាធរខេត្តតាកែវសំរេចបែងចែកដីអោយលោក រ័ត្ន រុន តែម្នាក់ដល់ទៅពាក់កណ្តាលស្មើនឹងចំណែករបស់ភាគីម្ខាងទៀត ដែលមានគ្នាដល់ទៅ ៣នាក់ នោះពុំមានលក្ខណៈសមធម៌ទេ ។ ម្យ៉ាងទៀតលោក ជួប សែន ពុំបានប្តឹងឧទ្ធរណ៍ ពីសាលក្រមរបស់តុលាការខេត្តតាកែវទេ ឯលោក សោម គុណ ក៏ពុំដែលបានប្តឹងតវ៉ាពីការ សំរេចរបស់ខេត្តដែរ ដូច្នេះលោក ជួប សែន និង សោម គុណ ពុំអាចទាមទារអ្វីលើសពីនេះ បានឡើយ ។ ប៉ុន្តែដោយលោក ប៊ូ សយ ពុំបានយល់ព្រមតាមការសំរេចរបស់អាជ្ញាធរខេត្តតាកែវ និង ការសំរេចរបស់តុលាការថ្នាក់ក្រោម តុលាការកំពូលគប្បីពិចារណាតាមសមធម៌បែងចែក ដីទំនាស់ជាបីចំណែកស្មើគ្នា ដោយមួយចំណែកប្រគល់អោយលោក រ័ត្ន រុន ពីរចំណែកទៀត

ប្រគល់អោយភាគីលោក ប៊ូ សយ ជួប សែន និង សោម គុណ ៗ ប៉ុន្តែចំណែកដែលបានទទួលលើសពី ការសំរេចរបស់អាជ្ញាធរខេត្តតាកែវត្រូវបានទៅលើលោក ប៊ូ សយ ទាំងអស់ ។

- យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ៧៩៧ ចុះថ្ងៃទី ០៨ ខែវិច្ឆិ-ការ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំង គតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៥៣៤ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់លោក ប៊ូ សយនិងលោក ជួប សែន ទុកជាត្រឹមត្រូវតាមទំរង់ នឹង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៧៩៧ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- ប្រគល់ដីទំនាស់នៅទេ-ទី១ ,២ ,៤ ចំនួន២ភាគ៣ អោយលោក ប៊ូ សយ លោក ជួប សែន និង សោម គុន កាន់កាប់គ្រប់គ្រងទៅសល់ចំណែក ១ភាគ៣ ទៀតប្រគល់អោយលោក រ័ត្ន រុណ កាន់កាប់ និង គ្រប់គ្រង ប៉ុន្តែនៅក្នុងចំណែក ២ ភាគ ៣ ដែលត្រូវបានទៅភាគីលោក ប៊ូ សយ ,ជួប សែន និង សោម គុន ដែលមានទំហំលើសពីការបែងចែករបស់អាជ្ញាធរខេត្តតាកែវត្រូវបានទៅលើលោក ប៊ូ សយ ទាំងអស់ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក រ័ត្ន រុន បានបង់ជូនរួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល

- បង្គាប់អោយលោក រ័ត្ន រុន លោក ប៊ូ សយ និង លោក ជួប សែន រួមគ្នាបង់ពន្ធសមាមាត្រ ១ភាគរយ លើតម្លៃដីទំនាស់ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០១ ។